# និរន្តរភាពវិស័យជលផលនៅក្នុងបឹងទន្លេសាប

## FHI 360/Global FISH Alliance

ព្រឹត្តិប័ត្រប្រចាំខែកក្កដា ឆ្នាំ២០១៣

## ទិវាមច្ឆាជាតិ

**ខេត្តកំពង់ធំ** ចំនួនកូនត្រីប្រមាណជាងមួយលានក្បាល ត្រូវបានដោះលែងចូលទៅក្នុងអាងទឹកស្ទឹងជីនិត នៅខេត្តកំពង់ធំ នៅក្នុងកម្មវិធីទិវាមច្ឆាជាតិ ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី1 ខែកក្កដា ឆ្នាំ2013 ។

កម្មវិធីនេះត្រូវបានដឹកនាំ និងរៀបចំដោយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ដោយមានកិត្តិយសចូលរួម ក្រោមអធិបតិយ្យភាព ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី និងជាប្រធាននៃក្រុមប្រឹក្សាកសិកម្មនិងអភិវឌ្ឍន៍ជនបទ (CARD) ។ នេះគឺជាទិវាមច្ឆាជាតិលើកទី11ហើយដែលត្រូវបានប្រារព្ធធ្វើឡើង ហើយនេះក៏ជាឪកាសមួយដើម្បីបើកសម្ពោធវិទ្យាស្ថានវារីវប្បកម្មថ្នាក់ជាតិជាសាធារណៈ។

វិទ្យាស្ថានវារីវប្បកម្មជាតិនេះត្រូវបានបង្កើតឡើង ជាមួយនឹងការរួមចំណែកពីដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាល។ រដ្ឋាភិបាលរំពឹងទុកជាមុនថា វិទ្យាស្ថាននេះនឹងអាចមានសមត្ថភាពផលិតកូនត្រីចំនួន 20 លានក្បាលជារៀងរាល់ឆ្នាំផងដែរ។

កំពុងឈរនៅចំពោះមុខប្រជាជន និងមន្ត្រីរាជការជាងមួយពាន់នាក់ដែលចូលរួមក្នុងកម្មវិធី ឯកឧត្តម ច័ន្ទសារុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទបានថ្លែងថា«យើងសង្ឃឹមថា វិទ្យាស្ថានវារីវប្បកម្មជាតិនេះ នឹងទទួលបានជោគជ័យក្នុងការផលិតកូនត្រីឲ្យបានគ្រប់គ្រាន់ ដើម្បីបំពេញតាមតម្រូវការរបស់ប្រជាជន និងទប់ស្កាត់ត្រីពីការផុតពូជ"។ ឯកឧត្តមក៏បានបកស្រាយទាក់ទិននឹងសកម្មភាពនេសាទខុសច្បាប់ ព្រមទាំងមានប្រសាសន៍ណែនាំថា រាជរដ្ឋាភិបាលបានបង្ក្រាបសកម្មភាពនេសាទខុសច្បាប់ចំនួន 5307នៅក្នុងឆ្នាំនេះ។សកម្មភាពនេះបានកើនឡើងចំនួន 848ករណីចាប់តាំងពីឆ្នាំ2011 ។

បន្ទាប់ពីកំណែទម្រង់វិស័យជលផលស៊ីជម្រៅ រដ្ឋបាលជលផលបានបង្កើតតំបន់អភិរក្សចំនួន95 ដែល79 នៃតំបន់អភិរក្សទាំងនោះស្ថិតនៅក្នុងតំបន់ទឹកសាប។ បង្គោលព្រំដែនបេតុងមួយចំនួនធំត្រូវបានតម្លើងរួចរាល់ហើយនៅតំបន់អភិរក្សទាំងនោះ ហើយកន្លែងដែលពុំទាន់តម្លើងបង្គោលបេតុង ត្រូវបានតម្លើងបង្គោលឈើជាបណ្ដោះអាសន្នសិន។

បន្ទាប់ពីសុន្ទរកថារបស់ ឯកឧត្តម ចាន់សារុន ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ(CARD) បានប្រកាសទទួលស្គាល់សមិទ្ធិផលដែលក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍និងសហគមន៍បានធ្វើឡើង ក្នុងការការពារធនធានធម្មជាតិរបស់ប្រទេសកម្ពុជា និងបានលើកទឹកចិត្តដល់កិច្ចការបន្តនៃការខិតខំប្រឹងប្រែងនេះ។

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះសូមទាក់ទង ការិយាល័យរដ្ឋបាលជលផលនៅទីក្រុងភ្នំពេញ។*

#11, Street 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh

E-mail: gfishalliancecambodia@gmail.com
Tel: (855)89 555 313

# ត្រីដែកសំណាង

ភាពស្លេកស្លាំង ដែលជាស្ថានភាពបណ្តាលមកពីកម្រិតជាតិដែកទាបនៅក្នុងឈាម គឺជាលក្ខខណ្ឌដែលមានចំនួនប្រមាណ 40% នៃស្ត្រីនិង 60% នៃកុមារទូទាំងប្រទេសកម្ពុជា ហើយនិងអាចមានផលប៉ះពាល់សុខភាពធ្ងន់ធ្ងរ។ ដើម្បីជួយប្រយុទ្ធប្រឆាំងនឹងបញ្ហានេះក្នុងចំនោមប្រជាជនកម្ពុជា វិធីសាស្ត្រនៃការផ្គត់ផ្គង់កម្រិតជាតិដែកដល់សហគមន៍ជាពិសេសត្រូវបានដោះស្រាយ។ ដើម្បីជំនះនូវបញ្ហាសុខភាពនេះ គោលគំនិតសំខាន់នៃ**ត្រីដែកសំណាង** ដែលជាបំណែកតូចមួយនៃជាតិដែកត្រូវបានបង្កើតឡើងដូចជារូបរាងត្រី។

ការចម្អិនអាហារជាមួយនឹងជាតិដែកដើម្បីបង្កើនកម្រិតជាតិដែកក្នុងអាហារគឺមិនមែនជាគំនិតថ្មីនោះទេ នៅក្នុងឆ្នាំ 2008 សាកលវិទ្យាល័យGuelphនៃប្រទេសកាណាដា រួមជាមួយនឹងធនធានអភិវឌ្ឍន៍អន្តរជាតិ និងក្រសួងអភិវឌ្ឍន៍ជនបទបានចាប់ដៃគូដើម្បីស្វែងរកដំណោះស្រាយទៅនឹងបញ្ហានៃការកង្វះជាតិដែកនៅតំបន់ជនបទ ក្នុងប្រទេសកម្ពុជា។ លោកបណ្ឌិត គ្រីស្តូហ្វឺ (Christopher) លោក ឆាល (Charles) ជាមួយសហការី បានអភិវឌ្ឍគឺជាជម្រើសថ្មីមួយដែលគោលការណ៍ដ៏ដែល ដូចជាឆ្នាំងដែកចម្អិនម្ហូប ដែលនេះជាវិធីសាស្ត្រមួយ ត្រូវបានប្រើយ៉ាងទូលំទូលាយនៅក្នុងបណ្តាប្រទេសផ្សេងៗទៀតដើម្បីបង្កើនកម្រិតជាតិដែកក្នុងការចម្អិនអាហារ ទាំងនេះហើយដែលត្រីដែកសំណាងត្រូវបានបង្កើតឡើង។

**ត្រីដែកសំណាង** ត្រូវបានបង្កើតឡើងពីកំទេចជាតិដែកដោយមានគុណភាពខ្ពស់ និងបានបង្កើតឡើងដើម្បីឲ្យស្រដៀងទៅនឹងត្រីញញឹម។ ត្រីតូចដែលមានតម្លៃទាប និងមានសារជាតិគ្រប់សព្វនេះ ផ្តល់ភាពងាយស្រួលក្នុងការដាក់ចូលទៅក្នុងឆ្នាំងសម្លនៅពេលចម្អិនអាហារ ឬនៅក្នុងទឹកដាំសម្រាប់ផឹក ហើយអ្វីដែលត្រូវការនោះគឺរយៈពេលប្រមាណជា10 នាទីនៃពេលចម្អិនអាហារប៉ុណ្ណោះ។ ក្នុងអំឡុងពេលចម្អិនអាហារ ជាតិដែកនឹងសាយចេញយឺតៗដោយអត្រាថេរ ដែលអាច ផ្តល់នូវការផ្គត់ផ្គង់ជាតិដែកគ្រប់គ្រាន់សម្រាប់គ្រួសារទាំងមូល។ នៅចុងបញ្ចប់នៃដំណើរការនៃការចម្អិនអាហារនេះនាក់ដែលស្លរឬដាំទឹកអាចលាងវា ហើយដាក់វាដោយឡែករហូតដល់ថ្ងៃបន្ទាប់នៅពេលដែលពួកគេដាំទឹកបន្ថែមឬស្ល។ យកត្រីដែកសំណាងដាក់ចូលក្នុងទឹកជាមួយនឹងទឹកក្រូចឆ្មា ត្រូវបានរកឃើញថាជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពបំផុតដើម្បីបន្ថែមជាតិដែកទៅក្នុងរបបអាហារ។ ការបរិភោគទឹកស្អាតក្នុងមួយថ្ងៃចំនួនមួយលីត្របានបង្ហាញឲ្យឃើញថាជាតិដែកនៅក្នុងខ្លួនមានចំនួន75 ភាគរយដែលក្នុងខ្លួនត្រូវការជារៀងរាល់ថ្ងៃត្រូវបានបំពេញ។

ភាពស្លេកស្លាំងជាលក្ខខណ្ឌធម្មតាមួយដែលអាចប៉ះពាល់ដល់ការលូតលាស់ផ្នែករាងកាយ កំណើនការអភិវឌ្ឍនៅក្នុងខួរក្បាលកុមារ និងកម្រិតថាមពលរបស់បុគ្គលដូចជាជួយឱ្យអុកស៊ីសែនដឹកនាំឈាមទៅជុំវិញរាងកាយ។ ផលវិបាកមួយដ៏សំខាន់នៃភាពស្លេកស្លាំង និងប្រហែលជាធ្ងន់ធ្ងរបំផុតដែលនោះ គឺជាអត្រាស្លាប់របស់មាតាក្នុងអំឡុងពេលឆ្លងទន្លេ (hemorrhage postpartum)។ នៅពេលដែលការផ្ទុកជាតិដែកមាននៅក្នុងកម្រិតល្អ អ្នកនោះនឹងមានថាមពលកាន់តែច្រើនសមត្ថភាពទៅរៀនត្រូវបានបង្កើន និងអត្រាស្លាប់របស់មាតាគឺត្រូវបានកាត់បន្ថយក្នុងអំឡុងពេលមានផ្ទៃពោះនិងការមានផ្ទៃពោះបន្ទាប់ភ្លាមៗ។

អត្ថប្រយោជន៍ដ៏ធំនៃត្រីដែកសំណាងគឺមិនគ្រាន់តែព្យាបាលបុគ្គលនីមួយៗ ដូចថ្នាំគ្រាប់ជាតិដែកនោះទេ ប៉ុន្តែព្យាបាលសម្រាប់សមាជិកក្នុងគ្រួសារទាំងមូលទៀតផង។ ត្រីដែកសំណាង មានតំលៃថោកហើយប្រើបានរយៈពេលយូរជាងថ្នាំគ្រាប់ជាតិដែក។ ត្រីដែកសំណាងមានតំលៃប្រហែល $5.00 ប្រមាណ 20,000រៀល។ ត្រីមួយនេះត្រូវបានគេប៉ាន់ស្មានថាអាចប្រើក្នុងរយៈពេលដប់ឆ្នាំឬច្រើនជាងនេះ បើទោះបីជាត្រីនេះត្រូវបានបង្កើតឡើងពីជាតិដែក តែវាមិនច្រេះដោយសារតែវិធីសាស្ត្រនៃការទុកដាក់នោះទេ។

សព្វថ្ងៃនេះ លោកវេជ្ជបណ្ឌិត ឆាល ជាមួយសហការីរបស់លោកបានធ្វើការតាមដានសហគមន៍ចំនួនបួន ហើយលទ្ធផលនៃការសិក្សានេះ បានបង្ហាញថាត្រីដែកសំណាងបានបង្កើតឲ្យមានលទ្ធផលជាវិជ្ជមានក្នុងការព្យាបាលភាពស្លេកស្លាំង កម្រិតអេមោគ្លោប៊ីនក្នុងឈាមរបស់មនុស្សម្នាក់ៗបានសង្កេតឃើញថាត្រូវបានកើនឡើងជាមួយការផ្ទុកជាតិដែក។ សមាជិកគម្រោងនេះ បានរួមចំនែកក្នុងការពង្រីកគម្រោង ដើម្បីផលិតត្រី 10,000 បន្ថែមទៀតសំរាប់ស្រុកពីរនៅក្នុងខេត្តកណ្តាលនិងនៅទូទាំងប្រទេស។ គេសង្ឃឹមថានៅក្នុងរយៈពេល4ទៅ5ឆ្នាំបន្ទាប់ ត្រីដែកសំណាងនឹងអាចរកបាននៅទូទាំងប្រទេសកម្ពុជា។ *ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះសូមចូលទៅគេហទំព័រ www.luckyironfish.com។*

# អង្គការ សម្ពន្ធ័ត្រីពិភពលោក (G-FISH)ផ្តល់ការគាំទ្រដល់សកម្មភាពល្បាត នៅសហគមន៍ផាត់សណ្តាយ និងសហគមន៍ពាមបាង

អង្គការសម្ពន្ធ័ត្រីពិភពលោក (G-FISH) នឹងផ្តល់ការគាំទ្រសកម្មភាពល្បាតដល់សហគមន៍នេសាទចំនួនពីរ នៅលើបឹងទន្លេសាបក្នុងខេត្តកំពង់ធំគឺសហគមន៍នេសាទផាត់សណ្តាយនិងសហគមន៍នេសាទពាមបាង។ អង្គការG-FISHនឹងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់មន្ត្រីអនុវត្តនិងសមាជិកសហគមន៍នេសាទដើម្បីធ្វើសកម្មភាពល្បាតនៅក្នុងអំឡុងខែកក្កដានិងសីហាឆ្នាំ 2013 ទៅដល់សហគមន៍ទាំងពីរនេះ។ អង្គការG-FISH នឹងផ្តល់ការគាំទ្រ ទៅលើថ្លៃអាហារ និងថ្លៃប្រេងដល់ក្រុមល្បាត។

ចាប់តាំងពីកំណែទម្រង់វិស័យជលផលត្រូវបានកែប្រែនៅក្នុងខែមិនាឆ្នាំ 2012 និងឡូត៍នេសាទត្រូវបានបំបែកទៅជាតំបន់សហគមន៍នេសាទ និងតំបន់អភិរក្ស។ បន្ទាប់មកសហគមន៍នេសាទមានសកម្មភាពយ៉ាងខ្លាំងក្លាដើម្បីចូលរួមក្នុងការគ្រប់គ្រងតំបន់នេសាទសហគមន៍របស់ពួកគេ។ រដ្ឋាភិបាលបានផ្តល់ជូននូវកញ្ចប់ថវិកានិងការគាំទ្រមួយចំនួនដើម្បីជួយដល់សកម្មភាពល្បាតរបស់សហគមន៍នេសាទ តែទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានគំលាតនៅក្នុងការអនុវត្ត។

គោលដៅចំបងនៃសកម្មភាពល្បាតនេះ គឺនឹងអាចជួយដល់សហគមន៍ ក្នុងការបង្កើត ឬការសំរេចបាននូវប្រព័ន្ធយាមល្បាតដោយខ្លួនឯង និង អនុញ្ញាតឲ្យពួកគេមានលទ្ធភាពក្នុងការគ្រប់គ្រងធនធានជលផល ឲ្យមានប្រសិទ្ធភាពនិងឲ្យមានទំនុកចិត្តក្នុងការគ្រប់គ្រងដោយឯករាជ្យ។

សហគមន៍នេសាទពាមបាងនឹងធ្វើសកម្មភាពល្បាតរបស់ពួកគេនៅក្នុងតំបន់ចំនួនបី៖

1. បាក់ដាវ និងព្រៃកកងម៉ី
2. ដូនស្តើង
3. តាវ៉ើយ៖ ព្រៃកខ្វាវតាស្វ និងព្រៃកទទឹងថ្ងៃ

សហគមន៍នេសាទផាត់សណ្តាយនឹងធ្វើសកម្មភាពល្បាតរបស់ពួកគេនៅក្នុងតំបន់ចំនួនបួន៖

1. បឹងអភិរក្សក្បាលព្រួស
2. ស្ទឹងសែន៖ ពីផាត់សណ្តាយទៅដល់ព្រះគន្លង
3. អតីតឡូត៍នេសាទលេខ2
4. អតីតឡូត៍នេសាទលេខ3

សមាជិកសហគមន៍នេសាទទាំងពីរនាក់ នឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរនៅក្នុងសហគមន៍របស់ពួកគេដើម្បីធ្វើការសកម្មភាពល្បាត។ ដើម្បីធានាថាធនធានធម្មជាតិរបស់ពួកគេត្រូវបានការពារបានយ៉ាងល្អ ក្រុមល្បាតនឹងត្រូវធ្វើសកម្មភាពល្បាតយ៉ាងហោចណាស់ពីរដងក្នុងមួយសប្តាហ៍។ អ្នកសម្របសម្រួលសកម្មភាពល្បាតសម្រាប់សហគមន៍នីមួយៗនឹងផ្តល់ជូននូវរបាយការណ៍ដ៏ទៀងទាត់មកកាន់អង្គការG-FISH នៅរាជធានីភ្នំពេញសម្រាប់សកម្មភាពល្បាតនិមួយៗ។

អង្គការG-FISHសង្ឃឹមថាសហគមន៍នេសាទទាំងពីរ អាចធ្វើការដោយឯករាជ្យបន្ទាប់ពីការបញ្ចប់គម្រោងនេះ និងសកម្មភាពនឹងអាចជួយបង្កើនជំនាញក្នុងការល្បាតរបស់ពួកគេ។ ជាមួយនឹងការសាកល្បងគម្រោងល្បាតចំនួនពីរខែនេះ អង្គការG-FISHក៏សង្ឃឹមដែរថា នឹងបានរៀនសូត្រពីសកម្មភាពនេះហើយនិងចែករំលែកចំណេះដឹងនិងបទពិសោធន៍ដែលទទួលបានជាមួយនឹងម្ចាស់ជំនួយដទៃទៀត ដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាល ។

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះ៖ សូមទាក់ទងលោកស្រី Jeanette ROBINSON ប្រធានកម្មវិធីរបស់អង្គការG-FISH នៅកម្ពុជា។*

#11, Street 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh

E-mail: gfishalliancecambodia@gmail.com
Tel: (855)89 555 313

# គំរោងស្តារដាំព្រៃកោងកាងឡើងវិញ

អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល(FACT)បានធ្វើការលើគំរោងស្តារនិងដាំព្រៃលិចទឹកឡើងវិញនៅក្នុងខេត្តកំពត ដែលគម្រោងនេះត្រូវបានផ្តល់ជំនួយដោយគម្រោងមូលនិធិគាំទ្រលើការស្តារព្រៃកោងកាងនៅតំបន់អាស៊ីអាគ្នេយ៍(GNF) និងក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ចនៃប្រទេសអាឡឺម៉ង់។ នាពេលថ្មីៗនេះប្រធានបទដែលបានលើកឡើងយកមកប្រជុំនៅថ្ងៃទី28 ខែឧសភា ឆ្នាំ2013។ ការប្រជុំនេះមានប្រធានបទថា "ភាពរីកចម្រើនគម្រោងស្តាព្រៃកោងកាងឡើងវិញនៅតំបន់អាស៊ីអាគ្នេយ៍" ដែលមានគោលបំណង ដើម្បីចែករំលែកនូវពត៌មាន ពីការស្តារ និងការដាំកូនព្រៃកោងកាឡើងវិញនៅឃុំត្រពាំងសង្កែ ក្នុងខេត្តកំពត។ គំរោងនេះបានផ្តល់ឪកាសឲ្យសហគមន៍ក្នុងការកសាងសមត្ថភាព និងជួយលើកកម្ពស់ជីវភាពប្រជានេសាទឲ្យមានភាពប្រសើឡើង ដោយជួយបង្កើនចំនេះដឹងដល់សហគមន៍ ពីការអភិរក្ស ពីនិរន្តរភាព និងការការពារនៃជំរកធម្មជាតិ និងប្រព័ន្ធជីវចម្រុះ ។

ជីវភាពរបស់ប្រជានេសាទដែលរស់នៅតាមតំបន់ឆ្នេរ ត្រូវពឹងផ្អែកទាំងស្រុងទៅលើការនេសាទត្រី ពពួកគ្រំ ក្តាម ខ្យង និងនេសាទប្រភេទត្រីសមុទ្រផ្សេងៗទៀត។ ព្រៃកោងកាងនៅតំបន់ឆ្នេរ ដែលផ្តល់ជំរកសំរាប់ត្រី និងសត្វសមុទ្រដទៃទៀត ហេតុដូច្នេះហើយបានជាវាមានសារៈសំខាន់ដើម្បីរក្សា និងការពារប្រភពអាហារនិងជីវភាពដ៏សំខាន់នេះទុក។

គ្រួសារដែលមកពី ឃុំត្រពាំងសង្កែ ខេត្តកំពតអាចរកបានប្រាក់ចំនូលពីការខំប្រឹងប្រែងដាំបន្លែ ផ្លែឈើ និង ពីការលក់កូនឈើកោងកាងទៅឲ្យអ្នកដាំ។ ការអនុវត្តគម្រោងនេះបានត្រូវបានផ្តល់ឪកាសឱ្យស្ត្រីនិងកុមារនៅក្នុងសហគមន៍ចូលរួមសកម្មភាពជាច្រើន រួមមានការប្រមូលគ្រាប់ពូជកោងកាង ដាំដើមកោងកាង និងសាងសង់សួនបន្លែក្នុងតំបន់នេះ។ គំរោងស្តាដាំព្រៃកោងកាងឡើងវិញមិនត្រឹមតែបានជួយលើកកម្ពស់ជីវភាពប៉ុណ្ណោះទេ តែវាក៏ជួយកាត់បន្ថយបំរែបំរួលអាកាសធាតុផងដែរ ។

*ព័ត៌មានបន្ថែមទាក់ទិននឹងការងារនេះសូមទាក់ទងលោក ឌីម សារ៉ាត នាយកប្រតិបត្តិនៃអង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) ឬចូលទៅគេហទំព័រ www.fact.org.kh*។

###

#11, Street 302, Boeung Keng Kang I,
Khan Chamkamon, Phnom Penh

E-mail: gfishalliancecambodia@gmail.com
Tel: (855)89 555 313